**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្ត កំពង់ធំ**

លេខ៤៩៧២/១៨ សជណ

ថ្ងៃ ខែ អស្សុជ ឆ្នាំ ច សំរិទ្ធិស័ក ពុទ្ធសករាជ ២៥៦២

កំពង់ធំ,ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសមន្ត្រី ត្រួតពិនិត្យ មន្ត្រីសម្ភាសន៍ និងមន្ត្រីបម្រុង សម្រាប់អនុវត្តការងារជំរឿនទូទៅ ប្រជាជននៅខេត្តកំពង់ធំឆ្នាំ២០១៩

**យោង៖**- អនុក្រឹត្យលេខ៧១អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភាឆ្នាំ២០១៧ ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។

- សេចក្តីសម្រេចលេខ០៨១ សសរ/គជ បក ចុះថ្ងៃទី២២ខែឧសភា ឆ្នាំ២០១៨របស់គណកម្មការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។
- សេចក្តីសម្រេចលេខ ១២២/១៨ស.ស.រ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការជំរឿនទូទៅប្រជាជននៅខេត្តកំពង់ធំឆ្នាំ២០១៩។

គណៈកម្មាធិការជំរឿនទូទៅប្រជាជននៅខេត្តកំពង់ធំ សូមជូនដំណឹងដល់សាធារណជន មន្ត្រីរាជការតាមបណ្តាមន្ទីរ អង្គភាព រដ្ឋបាលក្រុង/ស្រុក ឃុំ/សង្កាត់ ប៉ុស្តិ៍រដ្ឋបាលឃុំ/សង្កាត់ ព្រមទាំងសិស្ស និស្សិត ទូទាំងខេត្តឲ្យបានជ្រាបថា គណៈកម្មាធិការជំរឿនទូទៅប្រជាជននៅខេត្តកំពង់ធំត្រូវការជ្រើសរើសមន្ត្រីកិច្ចសន្យាបម្រើការងាររយៈពេល ខ្លីក្នុងមុខតំណែងដូចខាងក្រោម៖

១. មន្ត្រីត្រួតពិនិត្យចំនួន ៤៤៦ នាក់

២. មន្ត្រីសម្ភាសន៍ចំនួន ១.៧៨៤ នាក់

៣. មន្ត្រីបម្រុង ចំនួន ៣៦ នាក់

**លក្ខខណ្ឌជ្រើសរើស៖**

- បេក្ខជនត្រូវមានទីលំនៅក្នុងតំបន់មូលដ្ឋានជំរឿនផ្ទាល់
- មានចំណេះដឹងទូទៅ និងបទពិសោធន៍ការងារអង្កេត ជំរឿន ឬការងារប្រហាក់ប្រហែល

កាលបរិច្ឆេទ៖

- ចាប់ផ្តើមទទួលពាក្យស្នើសុំ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៨
- ផុតកំណត់ទទួលពាក្យស្នើសុំថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៨

សេចក្តីដូចបានជម្រាបជូនខាងលើនេះសូម លោក លោកស្រី យុវជន យុវនារី សិស្ស និស្សិត ដែលមានបំណងចង់បំរើការងារជាមន្ត្រីជំរឿនទូទៅប្រជាននៅខេត្តកំពង់ធំតាមមុខតំណែងដូចបានរៀបរាប់ខាងលើ អញ្ជើញ មកទំនាក់ទំនងព័ត៌មាន និងដាក់ពាក្យស្នើសុំនៅការិយាល័យស្ថិតិនៃមន្ទីរផែនការខេត្តកំពង់ធំ ឬនៅតាមការិយាល័យផែនការស្ថិតិក្រុង/ស្រុក រៀងរាល់ម៉ោងធ្វើការ។

អភិបាលខេត្ត

ហ្វូន ម៉ាន់និត

ចម្លងជូន៖

- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- ក្រុមប្រឹក្សាខេត្ត

"ដើម្បីជូនជ្រាប"

- គ្រប់ក្រុងស្រុក
- មន្ទីរអង្គភាពជុំវិញខេត្ត

"ដើម្បីជួយផ្សព្វផ្សាយ"

- ឯកសារ កាលប្បវត្តិ